ខេមបូចា CambojA
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

## សេចក្តីថ្លែងការណ៍៖
## ខេមបូចាថ្កោលទោសចំពោះទង្វើអាជ្ញាធរខណ្ឌមានជ័យ ដែលបំពានសិទ្ធិអ្នកសារព័ត៌មាន

ភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២១ – នៅម៉ោង ៩:១០នាទីព្រឹក ថ្ងៃសុក្រ ទី១៣ ខែសីហានេះ កម្លាំងសមត្ថកិច្ចអាជ្ញាធរខណ្ឌមានជ័យបានដកហូតបំណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានរបស់លោក អាន វិចិត្រ អ្នកយកព័ត៌មានរបស់ខេមបូចា ហើយបង្ខំឲ្យលោក និងអ្នកសារព័ត៌មានដែលជាសមាជិកខេមបូចាម្នាក់ទៀត លុបរូបភាព និងវីដេអូអំពីការតវ៉ារបស់ក្រុមប្រជាពលរដ្ឋក្នុងពេលកម្លាំងសមត្ថកិច្ចចម្រុះខណ្ឌមានជ័យចុះរុះរើលំនៅស្ថានរបស់ពលរដ្ឋក្នុងភូមិសន្សំកុសល២ សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ លោក អាន វិចិត្រ ថ្លែងប្រាប់ខេមបូចាថា សមត្ថកិច្ចថែមទាំងបានគំរាមរូបលោកថា ប្រសិនបើលោកមិនព្រមលុបរូបចោលទាំងអស់នៅចំពោះមុខសមត្ថកិច្ចទេ លោកនឹងត្រូវប្រឈមនឹងការឃាត់ខ្លួន។ លោកអាន វិចិត្រ បន្តថា ទោះបីជាលោកព្យាយាមបញ្ជាក់ប្រាប់ថា លោកជាអ្នកសារព័ត៌មានដោយបានបង្ហាញកាតអ្នកសារព័ត៌មានជូនសមត្ថកិច្ចយ៉ាងណាក៏ដោយ ក៏សមត្ថកិច្ចនៅតែបង្ខំឲ្យលោកលុបរូបទាំងអស់ចេញពីកាមេរ៉ារបស់លោក ហើយថែមទាំងបានដកហូតកាតសារព័ត៌មានរបស់គាត់យកទៅបាត់។ ទោះបីជាលោកព្យាយាមស្នើសុំវិញយ៉ាងណា ក៏សមត្ថកិច្ចនៅតែមិនព្រមប្រគល់មកឲ្យវិញ ដោយប្រាប់ថា ឱ្យលោកទៅយកនៅសាលាខណ្ឌ។

អ្នកសារព័ត៌មានមួយរូបទៀតឈ្មោះ លាស់ លីប លីប ដែលជាអ្នកសារព័ត៌មានកំពុងហ្វឹកហ្វឺន នៅវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) និងជាសមាជិករបស់ខេមបូចាដែរនោះ ក៏ត្រូវបានសមត្ថកិច្ចខណ្ឌមានជ័យដកហូតទូរស័ព្ទដៃយកទៅលុបរូបថត និងវីដេអូចោលដែរ។ លោកប្រាប់ខេមបូចាថា រូបថតជាច្រើនសន្លឹក និងវីដេអូអំពីសកម្មភាពឈូសឆាយរបងផ្ទះរបស់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរដែលលោកថតបាន ត្រូវសមត្ថកិច្ចលុបចោលទាំងអស់។ លោកបន្តថា បន្ទាប់ពីបានលុបរូប និងវីដេអូទាំងអស់ចោលរួច សមត្ថកិច្ចថែមទាំងបានសុំសោរម៉ូតូរបស់លោកយកទៅចាក់ដើម្បីឆែករកមើលកាមេរ៉ា និងទូរស័ព្ទផ្សេងទៀត ហើយបានយកទូរស័ព្ទរបស់លោកមួយគ្រឿងទៀតដែលលោករក្សាទុកនៅក្នុងកាបូបដែលលោកទុកលើម៉ូតូ ហើយបានលុបរូបដែលលោកបានថតចោលទាំងអស់ ទើបប្រគល់ទូរស័ព្ទ និងសោរម៉ូតូឱ្យលោកវិញ។ លោកបានហៅទង្វើរបស់សមត្ថកិច្ចដែលបានដកហូតទូរស័ព្ទដៃ និងលុបរូបរបស់គាត់ចោលទាំងកំរោលនេះថា ជាការរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពសារព័ត៌មាន និងបង្ហាញពីការរឹតត្បិតសេរីភាពសារព័ត៌មាន។ លោកថ្លែងថា អាជ្ញាធរកំពុងមានចេតនាលាក់បាំងការពិត ដោយហាមឃាត់អ្នកសារព័ត៌មាន ខណៈដែលប្រជាពលរដ្ឋកំពុងត្រូវការអ្នកសារព័ត៌មានផ្សព្វផ្សាយរឿងរ៉ាវពិតរបស់ពួកគាត់ជូនសាធារណជន។

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ហៅកាត់ថា ខេមបូចា ថ្លែងថា៖ «**ការដកបំណ្ណអ្នកសារព័ត៌មាន ការគំរាមកំហែង ការរារាំងមិនអនុញ្ញាតឲ្យពួកគាត់បំពេញតួនាទីភារកិច្ចបាន ជាការរំលោភបំពានធ្ងន់ធ្ងរទៅដល់សេរីភាពសារព័ត៌មាន ទៅដល់សិទ្ធិរបស់អ្នកសារព័ត៌មាន ហើយជាការរំលោភដល់សិទ្ធិរបស់ប្រជាពលរដ្ឋគឺសិទ្ធិទទួលបានព័ត៌មាន ។ សមត្ថកិច្ចអាជ្ញាធរគួរតែបើកចិត្តទូលាយ ហើយយល់ដឹងបន្ថែមទៀតអំពីភារកិច្ច កិច្ចការងាររបស់អ្នកសារព័ត៌មាន ជាពិសេសអ្នកសារព័ត៌មានវិជ្ជាជីវៈ អ្នកសារព័ត៌មានឯករាជ្យនេះ ដោយធ្វើយ៉ាងណាអនុញ្ញាតឲ្យគាត់បំពេញតួនាទីដោយសេរីស្របតាមច្បាប់ស្តីពីរបបសារព័ត៌មាន ស្របទៅតាម**

(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់យើង ។ ការប្រើប្រាស់នូវរូបភាពណាមួយក៏ដោយដើម្បីរឹតត្បិត ដើម្បីរារាំង គឺជាការរំលោភបំពានដល់ច្បាប់ស្តីពីរបបសារព័ត៌មានហើយជាការរំលោភបំពានទៅដល់រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់យើងដែលយើងមិនអាចទទួលយកបាន ។ ខ្ញុំក៏សូមអំពាវនាវដល់អាជ្ញាធរឲ្យបញ្ឈប់សកម្មភាពរារាំង ការធ្វើទុក្ខបុកម្នេញ ការគំរាមកំហែងមកលើអ្នកសារព័ត៌មានជាបន្ទាន់ ហើយផ្តល់ការសហការគ្នា ហើយនិងការគោរពទៅដល់ការអនុវត្តតួនាទី ការអនុវត្តសេរីភាពរបស់បងប្អូនអ្នកសារព័ត៌មានដើម្បីបង្ហាញទៅដល់សាធារណជនថា រដ្ឋាភិបាលមានការយកចិត្តទុកដាក់ ហើយនិងគោរពទៅដល់សិទ្ធិប្រជាពលរដ្ឋ ជាពិសេសសិទ្ធិទទួលបានព័ត៌មាន ។»

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ណុប វី**
នាយកប្រតិបត្តិ
០១២ ៥១៩ ២៦១
ed@camboja.net

**លោក ហ៊ឹម ខទៀត**
មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និង តស៊ូមតិ
០១៦ ៥៧៥ ៧១៣
khortieth.him@camboja.net